00636338

E18

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសង

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១


ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 18 / 01 / 2011
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak


**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង សាធារណៈ / Public

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

## សំណើសុំដោះលែងឲ្យមានសេរីភាព យោងតាមវិធាន ៨២ (៣) នៃវិធានផ្ទៃក្នុង

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក ស សូវាន

លោក Jacques VERGES

លោក Philippe GRECIANO

**ជំនួយការ៖**

កញ្ញា សេង សុជាតា

កញ្ញា Frédéric HIVON

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

លោក Archibald CELEYRON

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Mme Silvia CARTWRIGHT

ចៅក្រម យូ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និងដើមបណ្ដឹងរដ្ឋប្បវេណីគ្មានតំណាង**

## សូមគោរពអង្គជំនុំជម្រះសាលាដំបូង

### ១. សេចក្តីផ្តើម

១. កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញាបានដាក់នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជាភាសាអង់គ្លេស និងភាសាខ្មែរ ហើយបានស្នើសុំឱ្យមានការចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្នលើជនជាប់សង្ស័យចំនួនប្រាំនាក់ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលក្នុងនោះមានលោក ខៀវ សំផន ផងដែរ [1]។

២. កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ លោក ខៀវ សំផន ត្រូវបានចាប់ខ្លួន និងនាំខ្លួនមកចំពោះមុខសហចៅក្រមស៊ើបអង្កេត ក្នុងក្របខណ្ឌនៃការនាំខ្លួនលើកទីមួយ និងការដេញដោលចំពោះមុខ ដែលមានគោលដៅក្នុងការសម្រេចថាតើគាត់ត្រូវឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវដោះលែងឱ្យមានសេរីភាពនោះ។ បន្ទាប់ពីធ្វើការពិភាក្សាដេញដោលចំពោះមុខរួចមក និងដោយ "បានឃើញឯកសារជាច្រើន ព្រមទាំងកំណត់ហេតុរបស់សាក្សីនានាដែលបានដាក់ចូលក្នុងសំណុំរឿង"[2] សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឱ្យមានការឃុំខ្លួនបណ្តោះអាសន្ន រយៈពេលមួយឆ្នាំ លើរូប ខៀវ សំផន។

៣. នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ លោក ខៀវ សំផន បានដាក់នូវសំណើសុំបន្ទាន់ដើម្បីឱ្យមានការដោះលែងរូបលោកឱ្យមានសេរីភាព [3]។

៤. នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញនូវដីកាបដិសេធការដោះលែងឱ្យមានសេរីភាព[4] ដែលតាមរយៈដីកានេះ សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើសុំដោះលែង លោក ខៀវ សំផន ឱ្យមានសេរីភាព។ លោក ខៀវ សំផនក៏បានបានប្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាបដិសេធការដោះលែងឱ្យមានសេរីភាព[5]។

---

[1] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ *ឯកសារតុលាការ* D3។

[2] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ០៥ *ឯកសារតុលាការ* C26។

[3] សំណើសុំឱ្យមានការដោះលែងឱ្យមានសេរីភាពជាបន្ទាន់ *ឯកសារតុលាការ* C40។

[4] ដីកាសម្រេចបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព *ឯកសារតុលាការ* C40/4។

[5] សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធការដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ* C40/5/1។

៥. នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឲ្យធ្វើការបន្តថេរៈវេលាឃុំខ្លួន លោក ខៀវ សំផន[6] ដែលបានប្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹង ដីកាបដិសេធការដោះលែងឲ្យមានសេរីភាព [7]។

៦. កាលពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍ទាំងឡាយ ដែលប្រឆាំងនឹងដីកាបដិសេធការដោះលែងឲ្យមានសេរីភាព និងដីកាបន្តថេរៈវេលាឃុំខ្លួនបណ្តោះអាសន្ន [8]។

៧. តាមរយៈសេចក្តីជូនដំណឹងចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ "ជនត្រូវចោទ និងមេធាវីទាំងឡាយរបស់គេថា រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ដូចបានកំណត់ក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន (របស់សហចៅក្រមស៊ើបអង្កេត) ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ នឹងផុតកំណត់នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយសហចៅក្រមស៊ើបអង្កេតនឹងបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ននេះ [9]។

៨. នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ លោក ខៀវ សំផន បានសរសេររិះគន់ចំពោះសេចក្តីសម្រេចបន្តថេរៈវេលាឃុំខ្លួនបណ្តោះអាសន្ន [10]។

៩. នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឲ្យមានការបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ន [11]" ។

---

[6] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន *ឯកសារតុលាការ* C26/4។

[7] សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធការដោះលែងឲ្យមានសេរីភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ* C40/5/1។

[8] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឲ្យមានសេរីភាព និងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន *ឯកសារតុលាការ* C26/5/26។

[9] សេចក្តីជូនដំណឹង (វិធាន ៦៣.៧) *ឯកសារតុលាការ* C26/6។

[10] សេចក្តីជំទាស់នឹងការបន្តថិរវេលាឃុំខ្លួនជាបណ្តោះអាសន្ន លោក ខៀវ សំផន *ឯកសារតុលាការ* C26/7។

[11] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន *ឯកសារតុលាការ* C26/8។

១០. នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ លោក ខៀវ សំផន បានធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសម្រេចបន្តថេរៈវេលាឃុំខ្លួនបណ្ដោះអាសន្ន[12]។

១១. នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានបដិសេធបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងទៅនឹងដីកាសម្រេចបន្តថេរវេលាឃុំខ្លួនបណ្ដោះអាសន្ន [13]។

១២. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់នូវដីកាសន្និដ្ឋានស្ដាពរ ដោយសហព្រះរាជអាជ្ញាបានបង្គាប់ទៅសហចៅក្រមស៊ើបអង្កេតឱ្យធ្វើការចោទប្រកាន់ទៅលើឈ្មោះ ខៀវ សំផន ហើយបញ្ជូនខ្លួនទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះ ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងបទល្មើសនានាដោយផ្អែកលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ [14]។

១៣. ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ("ដីកា") ដែលតាមរយៈនោះសហចៅក្រមស៊ើបអង្កេតបានបង្គាប់ឱ្យបន្តឃុំខ្លួនលោក ខៀវ សំផន [15] ។

១៤. នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ លោក ខៀវ សំផនបានដាក់សារណាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ [16]។

១៥. នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានឆ្លើយទៅនឹងបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន [17]។

---

[12] សារណាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការពន្យារថិរវេលាឃុំខ្លួនបណ្ដោះអាសន្ន *ឯកសារតុលាការ* C26/9/1។

[13] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន *ឯកសារតុលាការ* C26/9/12។

[14] ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ *ឯកសារតុលាការ* D390។

[15] ដីកាដំណោះស្រាយ *ឯកសារតុលាការ* D427។

[16] សារណាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ *ឯកសារតុលាការ* ឯកសារ D427/4/3។

[17] ចម្លើយរបស់ សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ

១៦. នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ លោក ខៀវ សំផន បានឆ្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញា [18]

១៧. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានប្រកាសទទួលយកបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងដីកាដំណោះស្រាយ និងបញ្ជូន លោក ខៀវ សំផន ទៅកាន់អង្គជំនុំជម្រះសាលាដំបូង [19]

## ២. ការទទួលយកបណ្ដឹងឧទ្ធរណ៍

១៨. ដោយអនុលោមតាមវិធាន ៨២ (៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ("វិធានផ្ទៃក្នុង") "ជនជាប់ចោទ ឬ មេធាវីជនជាប់ចោទអាចស្នើសុំ (...) ដោយលិខិតជាលាយលក្ខណ៍អក្សរ ដាក់ជូនក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងឱ្យដោះលែងជនជាប់ចោទ"។

## ៣. បទបញ្ញត្តិគតិយុត្តិសមស្រប

១៩. វិធាន ៦៣ (៦) (ក) នៃវិធានផ្ទៃក្នុងអ.វ.ត.ក. ("វិធានផ្ទៃក្នុង") បានកំណត់ថេរវេលាអតិបរមានៃការឃុំខ្លួនបណ្ដោះអាសន្នមិនឱ្យលើសពីរយៈពេលមួយឆ្នាំ។ វិធាន ៦៣ (៧) បានអនុញ្ញាតឱ្យមានការបន្តថេរវេលានេះចំនួនពីរដង សម្រាប់ថេរវេលាសរុបបីឆ្នាំ។ វិធាន ៦៨(១) និង៦៨(៣) រួមគ្នានៃវិធានផ្ទៃក្នុង បានអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតបន្តថេរវេលាឃុំខ្លួនបណ្ដោះអាសន្នសម្រាប់រយៈពេលបន្ថែមបួនខែទៀត តាមរយៈការលើកឡើងក្នុងបញ្ញត្តិពិសេសនៃដីកាដំណោះស្រាយ។ វិធាន៦៨(៣)ចែងថា "ក្នុងករណីណាក៏ដោយ សេចក្ដីសម្រេចរក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្ដោះអាសន្ន ឬរក្សាលក្ខខណ្ឌនៃការដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គ

---

*ឯកសារតុលាការ* ឯកសារ D427/4/7។

[18] ចម្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញា *ឯកសារតុលាការ* ឯកសារ D427/4/13។

[19] ដីកាសម្រេចទាក់ទងទៅនឹងបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ *ឯកសារតុលាការ* ឯកសារ D427/4/14។

បុរេជំនុំជម្រះត្រូវអស់អានុភាពក្នុងរយៈពេល៤(បួន)ខែក្រោយ លើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលនោះ”។

២០. វិធាន ២ នៃវិធានផ្ទៃក្នុងចែងថា “នៅក្នុងអំឡុងពេលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើមានបញ្ហាណាមួយកើតមានឡើង ដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ (...) អង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្ត (...) ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ និង ច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន” ។

២១. វិធាន២១ នៃវិធានផ្ទៃក្នុងចែងថា “ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (...) ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ (...) ជនជាប់ចោទ (...) ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ។”

២២. មាត្រា៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា “ដូចមានចែងនៅក្នុងមាត្រា២៤៩ (សេចក្តីសម្រេចនៃដីកាដំណោះស្រាយ ទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ សេចក្តីសម្រេចរក្សាទុកខ្លួនជនជាប់ចោទ នៅក្នុងឃុំបណ្តោះអាសន្ន ត្រូវអស់អានុភាពនៃថិរវេលា៤ (បួន) ខែ។ ប្រសិនបើជនជាប់ចោទមិនត្រូវបានឱ្យចូលទៅបង្ហាញខ្លួន នៅមុខតុលាការ ក្នុងរយៈពេលនេះទេ ជនជាប់ចោទត្រូវតែបានដោះលែងឱ្យមានសេរីភាពឡើងវិញដោយឯកឯង”។

## ៤. ការផុតកំណត់នៃថេរវេលាដែលកំណត់ដោយច្បាប់

២៣. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ លោក ខៀវ សំផន ត្រូវបានចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ន។ សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្នត្រូវបាន**ពន្យារពេលចំនួនពីរដង** [20] រួចទៅ

[20] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន *ឯកសារតុលាការ* ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ C26/4, ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន *ឯកសារតុលាការ* ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ *ឯកសារ* C26/8។

ហើយ សម្រាប់ថេរៈវេលាមួយឆ្នាំ។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្ន លោក ខៀវ សំផន ដោយផ្អែកលើវិធាន ៦៨ (១) នៃវិធានផ្ទៃក្នុង ពោលគឺរហូតដល់ពេល លោក ខៀវ សំផន បង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[21] ។ វិធានផ្ទៃក្នុងបានចែងថា ការបង្ហាញខ្លួនរបស់ លោក ខៀវ សំផន ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ត្រូវធ្វើឡើងក្នុងរយៈពេល ៤(បួន)ខែ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេច រក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន។

២៤. ពីព្រោះថា វិធាន ៦៨ (៣) នៃវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា "ក្នុងករណីណាក៏ដោយ សេចក្តីសម្រេចរក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន (....) ត្រូវអស់អានុភាពក្នុងរយៈពេល ៤(បួន)ខែក្រោយ លើកលែងតែជនជាប់ចោទ ត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុង អំឡុងពេលនោះ"។ ការប្រើពាក្យ "ក្នុងករណីណាក៏ដោយ" ហើយរិតតែច្បាស់ជាងនេះទៅទៀត នៅក្នុងការប្រើពាក្យជាភាសាអង់គ្លេស "in any case" មិនបង្កើតនូវភាពមន្ទិលណាមួយ ដល់ការបកស្រាយវិធាននេះឡើយ។ ពាក្យនេះនអត្ថន័យថា ពុំមានករណី ណាមួយដែលគេអាចប្រព្រឹត្តផ្ទុយទៅនឹងបទបញ្ញត្តិនេះឡើយ។

២៥. ការបកស្រាយនេះកាន់តែមានបញ្ជាក់បន្ថែមទៀតតាមរយៈ មាត្រា ៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ មាត្រានេះមានចំណងជើងថា "ការបង្ហាញខ្លួនជនជាប់ចោទតាមដីកាបញ្ជូន ឬសាលដីកាបញ្ជូន" ហើយចែងថា "ដូចមានចែងនៅក្នុងមាត្រា២៤៩ (សេចក្តីសម្រេចនៃដីកាដំណោះស្រាយ ទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ សេចក្តីសម្រេចរក្សាទុកខ្លួនជនជាប់ចោទ នៅក្នុងឃុំបណ្តោះអាសន្ន ត្រូវអស់អានុភាពនៃថេរវេលា៤ (បួន) ខែ។ ប្រសិនបើជនជាប់ចោទមិនត្រូវបានឲ្យចូលទៅបង្ហាញខ្លួន នៅមុខតុលាការ ក្នុងរយៈពេលនេះទេ ជនជាប់ចោទត្រូវតែបានដោះលែងឲ្យមានសេរីភាពឡើងវិញដោយឯកឯង"។មកទល់នឹងថ្ងៃដែលពាក្យ បណ្តឹងនេះត្រូវបានធ្វើ ថេរវេលាលើសពីបួនខែបានកន្លងផុតទៅហើយ គឺចាប់តាំងពីដីកាសម្រេចនៃសហចៅក្រមស៊ើបអង្កេតក្នុងការរក្សាទុក លោក ខៀវ សំផន នៅក្នុងការឃុំខ្លួនជា

[21] ដីកាដំណោះស្រាយ *ឯកសារតុលាការ* កថាខណ្ឌទី១៦១៧ ដល់ទី១៦២៤ ឯកសារ D427។

បណ្តោះអាសន្ន តែលោក ខៀវ សំផន នៅតែពុំទាន់បាននាំខ្លួនទៅបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទៀត។

២៦. លោក ខៀវ សំផន ទទួលស្គាល់ថា ដីកាសម្រេចចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១[22] របស់អង្គបុរេជំនុំជម្រះ បានច្រានចោលបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ ឬដីកាបិទការស៊ើបសួរ។ ប៉ុន្តែដីកាសម្រេចនេះមិនអាចមានន័យថា បានកោះហៅរូបលោកទៅបង្ហាញខ្លួននៅមុខអង្គបុរេជំនុំជម្រះនោះទេ ។ ព្រោះថា ការបង្ហាញខ្លួនមានន័យថា "ជាការបង្ហាញខ្លួនដោយវត្តមានផ្ទាល់ចំពោះមុខអាជ្ញាធរតុលាការ[23]"។ វិធានផ្ទៃក្នុងជាភាសាអង់គ្លេសមានការប្រើប្រាស់ពាក្យនេះបានច្បាស់លាស់។ វិធាន ៦៨ (៣) នៃវិធានផ្ទៃក្នុងចែងថា "[I]n any case, the decision of the Co-Investigating Judges (…) to continue to hold the Accused in Provisional Detention (…) shall cease to have any effect after 4 (four) months unless the accused is **brought before** the Trial Chamber within that time."។ យើងមានការបកប្រែជាភាសាអង់គ្លេស បារាំង និងខ្មែរជាសក្ខីភាព [24] ហើយបើយោងតាមវិធាន ២១ នៃវិធានផ្ទៃក្នុង " វិធានផ្ទៃក្នុង (...) ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់(...) ជនជាប់ចោទ"។

២៧. យោងតាមវិធាន ៦៨ (៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្នលើរូបលោក ខៀវ សំផន របស់សហចៅក្រមស៊ើបអង្កេត បានអស់ប្រសិទ្ធិភាព។ ដូច្នេះ អង្គបុរេជំនុំជម្រះត្រូវតែបង្គាប់ឱ្យធ្វើការដោះលែងលោក ខៀវ សំផន អោយមានសេរីភាពជាបន្ទាន់។

---

[22] ដីកាសម្រេចទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់ លោក ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ *ឯកសារតុលាការ* ឯកសារ D427/4/14។

[23] CORNU (G.), *Vocabulaire juridique*, Presses universitaires de France, « Comparution », ទំព័រ១៨១ (ឧបសម្ព័ន្ធ)

[24] មាត្រា៤៥ នៃច្បាប់បង្កើត អ.វ.ត.ក ដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## ហេតុដូច្នេះ

២៨. លោក ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ៖

- **ជំនុំជម្រះ** លើករណីនេះឲ្យបានឆាប់
- **បន្ទាន់** ឲ្យដោះលែងរូបលោកឲ្យមានសេរីភាពជាបន្ទាន់

## រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

## និងដើម្បីយុត្តិធម៌

| | | | |
|---|---|---|---|
| | មេធាវី ស សូវាន | ភ្នំពេញ | |
| | មេធាវី Jacques VERGÈS | ប៉ារីស | |
| | មេធាវី Philippe GRECIANO | ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |